**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៥

នៅក្នុងខែឧសភា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកប ដោយស្មារតីទទួលខុសត្រូវខ្ពស់ ទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងសំណើរបស់គណៈកម្មការជំនាញ ដែលមានរបៀបវារៈ ដូចខាងក្រោម៖
  - ១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។
  - ២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានា ទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន បានយ៉ាន អេនើជី ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣០០មេហ្គាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។
  - ៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានា ទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន វេ សាន់ ស៊ី.អេ.ភី យូណាយធីត អ៊ិនវេសម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តបាត់ដំបង។
  - ៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានា ទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ផេល ប្ល ដត ឌីវេឡុបម៉ិន

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១២០មេហ្គាវ៉ាត់ នៅខេត្តព្រៃវែង។

៥- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន អេនើរើស ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

៦- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន វីស៊ីលាន មិរ៉ាយ ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

៧- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន សិនកៃ ភីវី អ៊ិនវេសម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ។

៨- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន តាំង ឡៃស៊ី អ៊ីមផត អិចផត សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

៩- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ផៅវ័ឌូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព២០០មេហ្គាវ៉ាត់ នៅខេត្តស្ទឹងត្រែង។

១០- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឆេមពាន គ្រុប ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

១១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ប៊ីលហ្វ្រេត ខនស្ត្រាក់សិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

១២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ច័ន្ទ និមល ឌីវេឡុបម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តកំពង់ចាម។

១៣-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ម៉ឌើនីធី ហូលឌីង សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។

១៤-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន អេច ខេ អូអេស៊ីស ផៅវ័រ អេនើជី ឌីវេឡុបម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

១៥-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

១៦-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឥណ្ឌូឆាយណា វីន ផៅវ័រ ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

១៧-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន លីឌើរ វីន អេនើជី (ខេមបូឌា) ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

១៨-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន គោព្រៃ វីនហ្វាម ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

១៩-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន បេជីង ហ្វេងហ្គ័ង អ៊ិនហ្វីនីត វីន អេនើជី ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

២០-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន អេសភីអេចភី (ខេមបូឌា) ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលជីវម៉ាស អានុភាព៥០មេហ្គាវ៉ាត់ និងស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៤០មេហ្គាវ៉ាត់ ផ្គួបគ្នា នៅខេត្តកំពង់ស្ពឺ។

២១-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន បុទុម សាគរ អេនើជី

ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយឧស្ម័នធម្មជាតិ អានុភាព ៩០០មេហ្កាវ៉ាត់ នៅខេត្តកោះកុង។

២២-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន អេនើស្ស ឯ.ក សម្រាប់គម្រោងវិនិយោគវារីអគ្គិសនីព្រែកល្ពាង១ និង២ អានុភាព១១០មេហ្កាវ៉ាត់ នៅខេត្តរតនគិរី។

២៣-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយប្រព័ន្ធអាគុយស្តុកទុកថាមពល អានុភាព២០០មេហ្កាវ៉ាត់ នៅខេត្តពោធិ៍សាត់ និងអានុភាព៣០០មេហ្កាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។

២៤-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយប្រព័ន្ធអាគុយស្តុកទុកថាមពល អានុភាព៥០០មេហ្កាវ៉ាត់ នៅខេត្តពោធិ៍សាត់។

២៥-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឆាយណា ណោសិនណល ហៅវី ម៉ាស៊ីនើរី សម្រាប់គម្រោងវិនិយោគវារីអគ្គិសនីបូមទឹកស្តុកទុក អានុភាព១០០០ មេហ្កាវ៉ាត់ នៅខេត្តកោះកុង។

២៦-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ជលផល និង

២៧-ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ ០០៩/០៥២៥/លគ.គក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៥ និងលេខ ០១១/០៥២៥/លគ.គក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២៥។

- បានរៀបចំបើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលមានរបៀបវារៈ ដូចខាងក្រោម៖

  ១- ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី និង

  ២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។

## ២-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- សកម្មភាពចូលរួមកិច្ចប្រជុំ៖
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងដឹកនាំសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំលើកទី១ និងលើកទី២នៃគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា និង

- បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារព័ត៌មានផ្សព្វផ្សាយរបស់សមាគមអតីតយុទ្ធជនកម្ពុជា (C.V.A) នៅវិមាន៧មករា។

- បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖ បានអនុញ្ញាតឱ្យ **ឧកញ៉ា តែ តាំងប៉** ប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមមូលនិធិ សម្តេចតេជោ ដើម្បីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមាន៧មករា។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល និងយាងទតការតាំងបង្ហាញផលិតផលកសិកម្ម ឧស្សាហកម្ម និងសិប្បកម្ម នៅទីព្រះស្រែកីឡដ្ឋានក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង និង
  - បានអញ្ជើញចូលរួមក្នុងពិធីបុណ្យទក្ខិណានុប្បទានខួបគម្រប់៣ឆ្នាំ ដើម្បីឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធ **សម្តេចឧត្តមទេពញាណ ហ៊ុន ណេង** នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- សកម្មភាពចូលរួមកិច្ចប្រជុំ៖
  - បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងចូលរួមសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ និងលើកទី២នៃគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា និង
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំការងាររួមជាមួយទីប្រឹក្សា និងសមាជិកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បេសកកម្មក្នុងប្រទេស៖ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីទេវតាពលី ពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងពិធីសម្ពោធឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលនានា នៅក្នុងសីមាវត្តជ្រៃបិទមាស ក្រុងសួង ខេត្តត្បូងឃ្មុំ។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅទីព្រះស្រែកីឡដ្ឋានក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង និង
  - បានអញ្ជើញជាអធិបតីក្នុងពិធីបិទអង្គសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លទ្ធផលនៃការងារការបរទេសរបស់កម្ពុជា និងសភាពការណ៍អន្តរជាតិ" នៅវិមានរដ្ឋសភា។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទង្សនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- សកម្មភាពចូលរួមកិច្ចប្រជុំ៖
  - បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងចូលរួមសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ និងលើកទី២នៃគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។
  - បានដឹកនាំកិច្ចប្រជុំពិភាក្សាដើម្បីសិក្សាស្រាវជ្រាវអំពីការពង្រឹងគណនេយ្យភាពសមាជិកព្រឹទ្ធសភាជាមួយអង្គបោះឆ្នោត នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - បានដឹកនាំកិច្ចប្រជុំជាមួយឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មការទាំង១០ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងគណៈកម្មការក្រុមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំដើម្បីពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវស្តីពី ប្រព័ន្ធព្រឹទ្ធសភានៅកម្ពុជា ប្រព័ន្ធព្រឹទ្ធសភាលោកខាងលិច និងប្រព័ន្ធព្រឹទ្ធសភានៅអាស៊ី នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំការងាររួមជាមួយទីប្រឹក្សា និងសមាជិកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖ បានអនុញ្ញាតឱ្យ **លោកស្រីបណ្ឌិត អេង នេត្រា** ប្រធានវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI) និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅសាលប្រជុំខុទ្ទកាល័យអនុប្រធានទី២ព្រឹទ្ធសភា។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញជូន និងទទួលដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា អញ្ជើញបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
  - បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញថ្លែងសុន្ទរកថាបិទវេទិកាផ្សព្វផ្សាយស្តីពី វឌ្ឍនភាពនៃការអនុវត្តប្រព័ន្ធគាំពារសង្គម នៅវិមានរដ្ឋសភា។
  - បានអញ្ជើញថ្លែងសុន្ទរកថាបិទវេទិកាផ្សព្វផ្សាយស្តីពី ការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន នៅវិមានរដ្ឋសភា។
  - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា សាស្ត្រាចារ្យ និងនិស្សិត មកពីសាកលវិទ្យាល័យជាតិ ចំនួន១០សាកលវិទ្យាល័យ ទស្សនាក្រុមហ៊ុន និងរោងចក្រស៊ី.ភី. ខេមបូឌា ចំកាត់ នៅខេត្តកំពង់ស្ពឺ និងរោងចក្រផលិតចំណីសត្វ នៅខេត្តកំពត។
  - បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញទស្សនារោងចក្រកែច្នៃគ្រាប់ស្វាយចន្ទី

(Welwilling Agricultural Technology Cambodia) នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។

- បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធ និងពិធីបញ្ចុះសព **ឯកឧត្តម មួង ប៉យ** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងជាសមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា នៅក្រុងបានលុង ខេត្តរតនគិរី និង
- បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធ និងពិធីបូជាសព **ឯកឧត្តម ទេព យុទ្ធី** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងជាលេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា នៅក្រុងកែប ខេត្តកែប។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅទីព្រះស្រែកីឡដ្ឋានក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។
- បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅសាលប្រជុំអគារក្រហម វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជូន និងទទួលដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា អញ្ជើញបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- បានអញ្ជើញចូលរួមជូន និងទទួលដំណើរ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ចូលរួមវេទិកាលើកទី៣នៃកិច្ចសន្ទនាសភា ត្បូង-ត្បូង (South-South Parliamentary Dialogue) ក្រោមប្រធានបទ កិច្ចសន្ទនាអន្តរតំបន់ និងទ្វីបនៅបណ្តាប្រទេសភាគខាងត្បូង ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ និងដើម្បីសម្រេចឱ្យបាននូវសន្តិភាព សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍរួម នៅព្រះរាជាណាចក្រម៉ារ៉ុក នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី ការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំអគាររដ្ឋបាលថ្មី វិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមសិក្ខាសាលាឈ្វេងយល់អំពីក្របខណ្ឌយុទ្ធសាស្រ្ត ក្នុងការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពី ប្រជាជន និងការអភិវឌ្ឍ-ICPD PoA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំអគាររដ្ឋបាលថ្មី វិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី លទ្ធផលនៃកិច្ចសហប្រតិបត្តិការ

អន្តរជាតិរបស់កម្ពុជា និងសភាពការណ៍អន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំអគាររដ្ឋបាលថ្មី វិមានរដ្ឋសភា។

- បានអញ្ជើញចូលរួមវេទិកាផ្សព្វផ្សាយស្តីពី ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំអគាររដ្ឋបាលថ្មី វិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី ការប្រកាសសមាសភាពគណៈកម្មការរៀបចំគណៈប្រតិភូសភាកម្ពុជា ចូលរួមកិច្ចប្រជុំ AIPA Caucus លើកទី១៦ និងសមាសភាពសមាជិកសភាវ័យក្មេង AIPA ដែលត្រូវចូលរួមកម្មវិធី AIPA Roadshow ក្រោមអធិបតីភាពរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** អនុប្រធានទី១រដ្ឋសភា និងជាប្រធានក្រុមរដ្ឋសភាកម្ពុជានៃអន្តរសភាអាស៊ាន (AIPA) នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាដើម្បីសិក្សាស្រាវជ្រាវអំពីការពង្រឹងគណនេយ្យភាពសមាជិកព្រឹទ្ធសភា ជាមួយអង្គបោះឆ្នោត ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំដើម្បីពិភាក្សាអំពីគណនេយ្យភាពនៅតាមភូមិភាគ និងពិភាក្សាអំពីការត្រៀមលក្ខណៈចូលរួមសមាជរដ្ឋសភា និងព្រឹទ្ធសភា ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមប្រជុំគណៈកម្មការពិសេសព្រឹទ្ធសភា ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានគណៈកម្មការពិសេស នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំជូនព័ត៌មានអំពីការរៀបចំប្រជុំសមាជរដ្ឋសភា និងព្រឹទ្ធសភាលើកទី១ នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារស្តីពី ការលើកកម្ពស់ការយល់ដឹងអំពីបញ្ញាសិប្បនិម្មិត (AI) និងអភិបាលកិច្ចឌីជីថល (Digital Governance) សម្រាប់ស្ថាប័នព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យលើខ្លឹមសារលើសេចក្តីព្រាងរបាយការណ៍ និងសេចក្តីព្រាងសេចក្តីសម្រេចរបស់សមាជស្តីពី ប្រព័ន្ធគាំពារសង្គម សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងវិស័យកសិកម្ម នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយគណៈកម្មការទី៧រដ្ឋសភា និងតំណាងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្តីពី ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដោយផ្តោតលើការអនុវត្តគោលនយោបាយវិស័យអប់រំ យុវជន និងកីឡា ក្រោមប្រធានបទ ការអភិវឌ្ឍមូលធនមនុស្ស ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ដែលគ្រោងរៀបចំរួមគ្នារវាងគណៈកម្មការទី៧ព្រឹទ្ធសភា និងគណៈកម្មការទី៧រដ្ឋសភា នៅសាលប្រជុំព្រះវិហារ វិមានរដ្ឋសភា។

- បានអញ្ជើញចូលរួមពិធីបុណ្យវិសាខបូជា ក្រោមអធិបតីភាពរបស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ នៅមុខព្រះសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ ខេត្តកណ្តាល។
- បានអញ្ជើញចូលរួមពិធីជួបសវនាការរវាង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា ជាមួយគណៈប្រតិភូក្រសួង និងគណៈប្រតិភូក្រុមហ៊ុនចំនួន៦ ក្នុងឱកាសខួបទី១៦២ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៥ និងខួបលើកទី៧០ឆ្នាំ នៃកាកបាទក្រហមកម្ពុជា ក្រោមមូលបទ រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។
- បានអញ្ជើញចូលរួមអម **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងពិធីបញ្ចុះសព **ឯកឧត្តម មួង ប៉យ** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងជាសមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា នៅខេត្តរតនគិរី និងសព **ឯកឧត្តម ទេព យុទ្ធី** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងជាលេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា នៅខេត្តកែប។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីសាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺទូទៅ ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅស្រុកស្អាង ខេត្តកណ្តាល មន្ទីរពេទ្យបង្អែកស្រុកស្រីសន្ធរ ស្រុកព្រៃឈរ និងអនុវិទ្យាល័យមិត្តភាពកម្ពុជា-ចិន ខេត្តកំពង់ចាម។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ **ចំនួន១១លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖

  ១/ ពិធីសម្ពោធអគារសិក្សា ១ខ្នង ៣ជាន់ ១៨បន្ទប់ និងសមិទ្ធផលនានា នៅក្នុងវិទ្យាល័យហ៊ុន សែន ប្រម៉ោយ នៅខេត្តពោធិ៍សាត់។

  ២/ ពិធីសំណេះសំណាលជាមួយសហជីពសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសមាគមបុគ្គលិកសិក្សា ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ។

  ៣/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារអន្តេវាសិកដ្ឋានតេជោសន្តិភាព និងសមិទ្ធផលនានា ក្នុងវត្តស្វាយពពែ នៅរាជធានីភ្នំពេញ។

  ៤/ ពិធីសម្ពោធបើកដំណើរការជាផ្លូវការរោងចក្រផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុនខនស៍ខេជី ស៊ីមេន (ភ្នំពេញ) ឯ.ក នៅខេត្តកំពង់ស្ពឺ។

  ៥/ ពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការ ផ្លូវជាតិលេខ៣១ ផ្លូវជាតិលេខ៣៣ និងផ្លូវជាតិលេខ៤១ ក្រោមក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការពីរាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅខេត្តតាកែវ។

  ៦/ ពិធីសំណេះសំណាលជាមួយមន្ត្រីរាជការ បុគ្គលិក កម្មករ និយោជិត កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០២៥ នៅខេត្តព្រះសីហនុ។

៧/ ពិធីបើកការដ្ឋានគម្រោងអភិវឌ្ឍន៍ប្រព័ន្ធចម្រោះទឹកកខ្វក់ក្នុងក្រុងតាខ្មៅ ក្រោមក្របខណ្ឌឥណទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ នៅខេត្តកណ្ដាល។

៨/ ពិធីសម្ពោធសមិទ្ធផលកំណែទម្រង់វិទ្យាស្ថានជាតិអប់រំ និងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត គរុនិស្សិត នៃវិទ្យាស្ថានជាតិអប់រំ នៅរាជធានីភ្នំពេញ។

៩/ ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងនឹងជំងឺមហារីក ឆ្នាំ២០២៥-២០៣០ នៅរាជធានីភ្នំពេញ។

១០/ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៨០ ថ្ងៃកំណើតនគរបាលជាតិកម្ពុជា នៅខេត្តកណ្ដាល និង

១១/ ពិធីសំណេះសំណាលជាមួយកម្មករនិយោជិតនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

- ❖ ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា **ចំនួន១០៥លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន ១៧៩លើក**។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងចូលរួមសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
  - អញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ និងលើកទី២នៃគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។
  - អញ្ជើញចូលរួមពិធីជួបជុំ និងពិសាអាហារសាមគ្គីជាមួយអ្នកសារព័ត៌មាន លើកទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំដោយក្រសួងព័ត៌មាន នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ (OCIC) រាជធានីភ្នំពេញ។
  - អញ្ជើញចូលរួមក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅទីព្រះស្រែកីឡដ្ឋានក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង និង

- អញ្ជើញចូលរួមក្នុងពិធីបុណ្យទក្ខិណានុប្បទានខួបគម្រប់៣ឆ្នាំ ដើម្បីឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធ **សម្តេចឧត្តមទេពញាណ ហ៊ុន ណេង** នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសមជាមួយ **ឧកញ៉ា តែ តាំងប៉** ប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមមូលនិធិ សម្តេចតេជោ ដើម្បីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា នៅវិមាន៧មករា។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំជូនព័ត៌មានអំពីការរៀបចំប្រជុំសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមជូន និងទទួលដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា អញ្ជើញបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង
- អញ្ជើញចូលរួមសហការរៀបចំចាត់ចែងពិធីបុណ្យសព **ឯកឧត្តម មួង ប៉យ** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងជាសមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា នៅក្រុងបានលុង ខេត្តរតនគិរី។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងចូលរួមសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
- អញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ និងលើកទី២នៃគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា និង
- អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ទេព យុទ្ធី** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងជាលេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា នៅក្រុងកែប ខេត្តកែប។

❖ **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមជូន និងទទួលដំណើរ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ចូលរួមវេទិកាលើកទី៣នៃកិច្ចសន្ទនាសភា ត្បូង-ត្បូង (South-South Parliamentary Dialogue) ក្រោមប្រធានបទ កិច្ចសន្ទនាអន្តរតំបន់ និងទ្វីបនៅបណ្តាប្រទេសភាគខាងត្បូង ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ និងដើម្បីសម្រេចឱ្យបាននូវសន្តិភាព សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍរួម នៅព្រះរាជាណាចក្រម៉ារ៉ុក នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

- អញ្ជើញគោរពវិញ្ញាណក្ខន្ធ និងពិធីបូជាសព **ឯកឧត្តម ទេព យុទ្ធី** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងជាលេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា នៅក្រុងកែប ខេត្តកែប និង
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២លើក។

❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបានៈ

- អញ្ជើញចូលរួមសហការរៀបចំពិធីបុណ្យសព **ឯកឧត្តម ទេព យុទ្ធី** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងជាលេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា នៅក្រុងកែប ខេត្តកែប។
- អញ្ជើញចូលរួមក្នុងពិធីទេវតាពលី ពិធីសូត្រមន្ត ចម្រើនព្រះបរិត្ត និងពិធីសម្ពោធឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅវត្តជ្រៃបិទមាស ក្រុងសួង ខេត្តត្បូងឃ្មុំ និង
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២លើក។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លានៃព្រះរាជពិធីបុណ្យចម្រើន **ព្រះជន្មព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់ ៧២ព្រះវស្សា យាងចូល ៧៣ព្រះវស្សា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងឱកាសដ៏នក្ខត្តឫក្សបំផុត ដែល **សម្តេចតេជោ** បានទទួលគ្រឿងឥស្សរិយយសកម្រិតខ្ពស់បំផុត "Grand Collar of the Order of Timor-Leste" ពីសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរព្រះរាជគុណ អំណរព្រះគុណ និងអរគុណរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងថ្វាយ ប្រគេន គោរពជូន និងជូន សម្តេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយ សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ សម្តេចព្រះរាជាគណៈ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ និងសមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័នសាធារណៈ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រីនៃវិស័យឯកជន និងសង្គមស៊ីវិល ព្រមទាំងជនរួមជាតិខ្មែរ ក្នុងឱកាសដែល **សម្តេចតេជោ** ត្រូវបាន **ឯកឧត្តម ចូហ្សេរ៉ាមូស-អរតា** ប្រធានាធិបតីទីម័រឡេស្តេ បំពាក់គ្រឿងឥស្សរិយយស "Grand Collar of the Order of Timor-Leste" ដែលជាឥស្សរិយយសកម្រិតខ្ពស់បំផុត នៅវិមានប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូន **ឯកឧត្តម ជា សុផារ៉ា** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលឯកឧត្តមត្រូវបាន ព្រះចៅអធិរាជជប៉ុន ប្រទាន និង យាងបំពាក់ផ្ទាល់នូវគ្រឿងឥស្សរិយយស។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា គោរពជូន **សម្តេច ឥស្សរវិទេសបញ្ញា ហោ ណាំហុង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ដែលត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទានគោរមងារជា "**សម្តេច ឥស្សរវិទេសបញ្ញា ហោ ណាំហុង**"។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គោរពជូន៖
  - **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានកិត្តិយសនៃក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
  - **ឯកឧត្តម យឹម ឆៃលី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
  - **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
  - **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
  - **ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
  - **លោកជំទាវ ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង
  - **ឯកឧត្តម សរ ចំរុង** ប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹងនិងអង្កេត និង អធិការកិច្ចនៃរដ្ឋសភា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន៖
  - **លោកជំទាវ ម៉ី សុខ** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តម ទេព យុទ្ធី** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងជាលេខាធិការគណៈកម្មការទី៨ ព្រឹទ្ធសភា។
  - ក្រុមគ្រួសារសព **លោកព្រិន្ទបាលឯក សួន រ៉ាន** ចំពោះការទទួលមរណភាពក្នុងហេតុការណ៍ផ្ទុះអាវុធរវាងកងទ័ពកម្ពុជា-ថៃ នៅព្រំដែនតំបន់មុំបី ស្ថិតនៅភូមិតេជោមរកត ឃុំមរកត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និង
  - ក្រុមគ្រួសារសព **កញ្ញា ដួង ម៉ាហ្គាលី** និង**លោក ផាត មុន្នី** នៃកងអនុសេនាធំរាជអាវុធហត្ថលេខ៨៧២ ប្រចាំប្រទេសស៊ូដង់ខាងត្បូង ចំពោះការទទួលមរណភាពក្នុងឧបទ្ទវហេតុផ្ទុះអាវុធក្នុងទីក្រុង Malakal ដែលជាកន្លែងឈរជើងរបស់កងរាជអាវុធហត្ថកម្ពុជា។

- បានធ្វើបទបង្ហាញស្តីពី "រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសារៈតារបស់ព្រឹទ្ធសភា " ប្រគេនព្រះសង្ឃ និងជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យជាតិបាត់ដំបង ចំនួន៩៧អង្គ/នាក់។
- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃ ចំនួន៨០កញ្ចប់ ក្នុងពិធីបុណ្យវិសាខបូជា។
- បានប្រគល់ថវិកាឧបត្ថម្ភរបស់ព្រឹទ្ធសភា និងឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជូនកាកបាទក្រហមកម្ពុជា ក្នុងឱកាសខួបលើកទី១៦២ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៥ និងខួបលើកទី៧០ឆ្នាំនៃកាកបាទក្រហមកម្ពុជា និង
- បានទទួលពាក្យបណ្តឹង ចំនួន៨បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង-ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៨បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ចំនួន ២បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន៩បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៩បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន១បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន៩បណ្តឹង និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន២បណ្តឹង។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖
  - បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម ចំនួន៥លើក រួមមាន៖

    ១/ **ឯកឧត្តម យ៉ាស៊ូតូស៊ី នីស៊ីមូរ៉ា** សមាជិកសភាជប៉ុន និងជាអតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន នៅវិមានព្រឹទ្ធសភា។

    ២/ **ឯកឧត្តមបណ្ឌិត អុក សូ ផាក** ស្ថាបនិកអង្គការសម្ព័ន្ធយុវជនអន្តរជាតិ (IYF) នៅវិមានព្រឹទ្ធសភា។

    ៣/ **ឯកឧត្តម ឯក ណាត ជាកាល់** អគ្គលេខាធិការនៃសន្និសីទប្រធានសភានៃអន្តរសភា (ISC) នៅវិមានព្រឹទ្ធសភា។

    ៤/ **ឯកឧត្តម អ៊ីហ្គ័រ ក្រសនៅ** អគ្គរដ្ឋអាជ្ញានៃសហព័ន្ធរុស្ស៊ី នៅវិមានព្រឹទ្ធសភា និង

    ៥/ **លោក អាគីរ៉ា ជូជាត** នាយកប្រតិបត្តិសាជីវកម្មទេសចរជប៉ុន នៅវិមានព្រឹទ្ធសភា។
- បេសកកម្មក្រៅប្រទេស៖
  - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា បំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ៖

    ១/ក្នុងឱកាសទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី **សម្តេចតេជោ** បាន៖

    + ជួបពិភាក្សាការងារជាមួយ៖
      - **ឯកឧត្តម ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី។
      - **ឯកឧត្តម កៅ គឹមហួន** អគ្គលេខាធិការអាស៊ាន តំណាងអចិន្ត្រៃយ៍ប្រទេសសមាជិកអាស៊ានទាំងអស់ និងលោកជំទាវឯកអគ្គរដ្ឋទូតទីម័រឡេស្តេ ប្រចាំអាស៊ាននៅលេខាធិការដ្ឋានអាស៊ាន។

- ○ **ឯកឧត្តមបណ្ឌិត មហាមេដ យូសុសកាឡា** អតីតអនុប្រធានាធិបតីឥណ្ឌូណេស៊ី និងជាប្រធានប្រតិបត្តិអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអាស៊ី-ប៉ាស៊ីហ្វិក។
- ○ **លោកសាស្ត្រាចារ្យបណ្ឌិត ដាតុ ស្រ៊ី ថាហ៊ា** សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់របស់ប្រធានាធិបតីឥណ្ឌូណេស៊ី និងស្ថាបនិកក្រុមហ៊ុន Mayapada Group។
- ○ **លោកជំទាវ ពាន់ ម៉ាហារ៉ានី** ប្រធានរដ្ឋសភានៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅវិមានរដ្ឋសភា និង
- ○ **ឯកឧត្តម ស៊ុលតាន់ បាកទីយ៉ា ណាចាមូឌីន** ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅវិមានព្រឹទ្ធសភា។

+ បានអញ្ជើញចូលរួមពិធីគម្រប់ខួបលើកទី២៦នៃព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកអាស៊ាន និងបានធ្វើបាឋកថា ក្រោមប្រធានបទស្តីពី "កម្ពុជា និងអាស៊ាន អាស៊ាន និងពិភពលោក" នៅរដ្ឋធានីហ្សាការតា។
+ បានអញ្ជើញធ្វើបាឋកថា ក្រោមប្រធានបទអំពី "ទស្សនៈ និងបទពិសោធន៍នៃកិច្ចខិតខំកសាងសន្តិភាពនៅកម្ពុជា" នៅវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា (ERIA) និង
+ បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ទស្សនាវិមានរដ្ឋសភាឥណ្ឌូណេស៊ី នៅរដ្ឋធានីហ្សាការតា។

២/ក្នុងឱកាសទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ **សម្តេចតេជោ** បាន៖

+ ជួបពិភាក្សាការងារជាមួយ៖
  - ○ **លោកជំទាវ ម៉ារៀ ហ្វើណាន់ដា ឡៃ** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅវិមានរដ្ឋសភា ទីក្រុងឌីលី។
  - ○ **ឯកឧត្តម កៃ រ៉ាឡា សាណាណា ហ្គូសម៉ៅ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅវិមានរដ្ឋាភិបាល និង
  - ○ **ឯកឧត្តម ចូហ្សេ រ៉ាមូស អរតា** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅវិមានប្រធានាធិបតី។
+ បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ទស្សនាកំពង់ផែ Tibar នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
+ បានអញ្ជើញធ្វើបាឋកថា ក្រោមប្រធានបទ "មេរៀនរបស់ ហ៊ុន សែន៖ ពីរបបប្រល័យពូជសាសន៍ និងភាពក្រីក្រ ឆ្ពោះទៅកាន់សេរីភាព និងវិបុលភាព" ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ទីម័រឡេស្តេ នៅវិមានប្រធានាធិបតី និង
+ បានអញ្ជើញទទួលគ្រឿងឥស្សរិយយស Grand Collar of the Order of Timor-Leste ដែលជាឥស្សរិយយស កម្រិតខ្ពស់បំផុតរបស់រដ្ឋាភិបាលទីម័រឡេស្តេ។

- ❖ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា៖
  - បេសកកម្មក្រៅប្រទេស៖
    - បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និង
    - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ចូលរួមវេទិកាលើកទី៣នៃកិច្ចសន្ទនាសភាត្បូង-ត្បូង (South-South Parliamentary Dialogue) ក្រោមប្រធានបទ កិច្ចសន្ទនាអន្តរតំបន់ និងទ្វីបនៅបណ្តាប្រទេសភាគខាងត្បូង ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ និងដើម្បីសម្រេចឱ្យបាននូវសន្តិភាព សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍរួម នៅព្រះរាជាណាចក្រម៉ារ៉ុក។
- ❖ **ឯកឧត្តមបណ្ឌិត ឆន់ ខឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា៖
  - បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖
    - បានអនុញ្ញាតឱ្យ **លោកស្រី តូម៉ូកូ ហ្វជីហ៊ីរ៉ា** អគ្គនាយកផ្នែកទីផ្សារនៃក្រុមហ៊ុន SuRaLa Net នៅបរទេស ដែលជាក្រុមហ៊ុនផ្តល់សេវាអប់រំ តាមប្រព័ន្ធអ៊ីនធឺណិត (E-Learning) ចំពោះសិស្សពីកម្រិតបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ចូលជួបពិភាក្សាការងារ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
    - បានអនុញ្ញាតឱ្យ **ឯកឧត្តម អាណាតូលី បូរ៉ូវិក** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - សកម្មភាពចូលរួមពិធីផ្សេងៗ៖ បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ជិន ទឹក លឿង** អតីតសមាជិកការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាម និងជាអតីតប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា រាជធានីភ្នំពេញ។
- ❖ **ឯកឧត្តម យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានចូលរួមកិច្ចប្រជុំអនុគណៈកម្មការបណ្តាញសមាជិកសភាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនៃសភាប្រើភាសាបារាំង (APF) ក្រោមអធិបតីភាពរបស់ **លោក ឡូរ៉ង់ វ៉េលលី** សមាជិកតំណាងរាស្ត្រស្វីស និងជាប្រធានបណ្តាញសមាជិកសភាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនៃសភាប្រើភាសាបារាំង (APF) ដោយផ្សាយចេញពីទីក្រុងប៉ារីស សាធារណរដ្ឋបារាំង តាមប្រព័ន្ធនិម្មិត នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- ❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញទទួលជួបអ្នកវិនិយោគជនជាតិជប៉ុន ដើម្បីសិក្សាឈ្វេងយល់ពីវិស័យកសិកម្ម ទេសចរណ៍ បរិស្ថាន អភិវឌ្ឍន៍ធម្មជាតិ និងទីតាំងផលិតជីធម្មជាតិ ព្រមទាំងទស្សនកិច្ចក្នុងតំបន់រមណីយដ្ឋានកសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅខេត្តកំពង់ស្ពឺ។

- ❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និងជាប្រធានគណៈកម្មការនយោបាយនៃក្រុមសភាជាតិកម្ពុជា APF និងជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យ និងតាមដាននៅក្នុងគណៈកម្មការនយោបាយ APF បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ និងតាមដាននៅក្នុងគណៈកម្មការនយោបាយ APF ក្រោមអធិបតីភាពរបស់ **ឯកឧត្តម អនទ្រេ រីកឆាត** សមាជិកព្រឹទ្ធសភាបារាំង និងជាប្រធានកិច្ចប្រជុំនោះ នៅសណ្ឋាគារ Noom Hôtel Dakar នៃសាធារណរដ្ឋសេណេហ្គាល់។
- ❖ **ឯកឧត្តម អាយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាសហប្រតិបត្តិការអន្តរសភាថ្នាក់តំបន់ស្តីពី "គោលនយោបាយអាកាសធាតុ" នៅព្រះរាជាណាចក្រថៃឡង់ដ៏។
- ❖ **ឯកឧត្តម អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ **លោកស្រី កូហ្គា អាស៊ូកា** និង**លោក អូនីស៊ី** លេខាធិការទី៣នៃស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាការងារ នៅបន្ទប់ឯកឧត្តមប្រធាន អគារF វិមានព្រឹទ្ធសភា។
- ❖ **ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានយាងចូលរួមសិក្ខាសាលាស្តីពី គោលនយោបាយអាកាសធាតុ នៅព្រះរាជាណាចក្រថៃឡង់ដ៏។
- ❖ **ឯកឧត្តម សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាអន្តរជាតិក្រោមប្រធានបទ "ទស្សនវិស័យក្នុងតំបន់ស្តីពី ព័ត៌មានមិនពិត និងឥទ្ធិពលរបស់វា" នៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក ទ្វីបអឺរ៉ុប និង
- ❖ **សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងជាព្រះធិបតីក្នុងពិធីសម្តែងក្បាច់រាំអន្តរជាតិរបស់និស្សិតសាកលវិទ្យាល័យ BYU ( Brigham Young University )សហរដ្ឋអាមេរិក នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - ▪ អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសមជាមួយភ្ញៀវអន្តរជាតិនានា នៅវិមានព្រឹទ្ធសភា ចំនួន២លើក។
  - ▪ អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ដោយក្នុងឱកាសទស្សនកិច្ចនោះ **ឯកឧត្តមអគ្គលេខាធិការ** បានអញ្ជើញចូលរួមអម **សម្តេចតេជោ** ទទួលជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងភ្ញៀវបរទេស ចំនួន៩លើក។
  - ▪ អញ្ជើញបំពេញទស្សនកិច្ចសិក្សានៅរដ្ឋសភា និងព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង តបតាមការអញ្ជើញ និងរៀបចំដោយមជ្ឈមណ្ឌលសភាអាស៊ី នៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង ដោយក្នុងឱកាសទស្សនកិច្ចនោះ **ឯកឧត្តមអគ្គលេខាធិការ** បានអញ្ជើញជួបពិភាក្សាការងារជាមួយសមាជិក សមាជិកាព្រឹទ្ធសភាបារាំង ចំនួន៣រូប រួមមាន៖
    - **ឯកឧត្តម** Olivier HENNO ប្រធានក្រុមមិត្តភាពអន្តរសភាអាស៊ីអាគ្នេយ៍-បារាំង។

- **លោកជំទាវ** Catherine BELRHITI ប្រធានប្រតិភូទទួលបន្ទុកក្រុមមិត្តភាពអន្តរសភា បារាំង-ថៃ និង
- **ឯកឧត្តម** Jean-Luc FICHET អនុប្រធានទទួលបន្ទុកក្រុមមិត្តភាពអន្តរសភា បារាំង-កម្ពុជា-ឡាវ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសម ជាមួយ **ឯកឧត្តម ឯក ណាត ដាកាល់** អគ្គលេខាធិការនៃសន្និសីទប្រធានសភានៃអន្តរសភា (ISC) នៅវិមានព្រឹទ្ធសភា។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូន **ឯកឧត្តម លឿង គឿង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និង**ឯកឧត្តម តូ លឹម** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម ចំពោះមរណភាព **ឯកឧត្តម ជិន ឌឹក លឿង** អតីតប្រធានាធិបតីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា គោរពជូន **ឯកឧត្តម** José Manuel Ramos-Horta ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ **ឯកឧត្តម** Kay Rala Xanana GUSMÃO នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និង**ឯកឧត្តម** Ermenegildo Kupa Lopes ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ក្នុងឱកាសដែលសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេនឹងដាក់បញ្ចូលជាសមាជិកពេញសិទ្ធិអាស៊ាន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧ នាខែតុលា ឆ្នាំ២០២៥ ខាងមុខនេះ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតគាំទ្ររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូន **ដូនជី** Raffaella Petrini ប្រធានអភិបាលបុរីវ៉ាទីកង់ ចំពោះព្រះរាជសុន្ទរកថាដំបូងរបស់ **សម្តេចប៉ាប** LÉON XIV ដែលបានអំពាវនាវទៅកាន់ពិភពលោកឱ្យប្រកាន់យកសន្តិភាព និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន បណ្ណសារដ្ឋានជាតិ និងក្រសួង-ស្ថាប័ននានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៤.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញទទួលជួប និងដឹកនាំកិច្ចប្រជុំជាមួយ **ឯកឧត្តមបណ្ឌិត ចន ណារិទ្ធ** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម

ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការកែទម្រង់របបសោធនសាធារណៈ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង

- អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

**៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

- បានរៀបចំរបាយការណ៍សមិទ្ធកម្មតាមជានអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពប្រចាំឆ្នាំ២០២៤ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានធ្វើលិខិតទូទាត់បុរេប្រទាន សម្រាប់ទិញរថយន្តថ្មី ជូនឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា និងការចុះបេសកកម្មក្រៅប្រទេសរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន៤បុរេប្រទាន។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែឧសភា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែឧសភា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ភិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា ឆ្នាំ២០២៥។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៨១សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន ១១៨សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៨សំណើ។
- បានថតចម្លងឯកសារ ចំនួន១,៦០៩ច្បាប់ និងចងក្រងធ្វើជាសៀវភៅ ចំនួន ២២ក្បាល ប្រើប្រាស់ក្រដាសអស់ ចំនួន២២,០៨១សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ៩៥លើក ស្មើនឹង២១៤នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៥លើក។
- បានទទួលលិខិតចូល ចំនួន៦២១ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៣៥៩ច្បាប់។

- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៥ច្បាប់ ស្មើនឹង១២០នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៧ច្បាប់។
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពី ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលអស់សុពលភាព ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តព្រៃវែង ចំនួន១០នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
    - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៥លើក។
    - បានកែលម្អសួនច្បារជុំវិញដងទង់ជាតិមុខអគារក្រហម ចំនួន៣៧០គុម្ព។
    - បានគាស់ដើមជ្រៃភ្នំដាំនៅសួនច្បារអគារ E ចំនួន៣២គុម្ព។
    - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា រួមមាន៖
    - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន៧១៦នាក់ (ប្រុស៤២៧នាក់ ស្រី២៨៩នាក់)។
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៧នាក់ (ប្រុស៥២នាក់ ស្រី៣៥នាក់)។
    - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩២នាក់ (ប្រុស៣០៩នាក់ ស្រី១៨៣នាក់)។
    - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន១២នាក់ និង
    - មន្ត្រីរាជការព្យួរនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
- បានធ្វើសេចក្តីសម្រេច ចំនួន៥ច្បាប់ និងលិខិតបង្គាប់ការ ចំនួន១ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្តង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៨ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែឧសភា ឆ្នាំ២០២៥។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១០នាក់ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី គោលនយោបាយប្រាស្រ័យទាក់ទង នៅវិមានរដ្ឋសភា។
- បានធ្វើបច្ចុប្បន្នភាព និងព្រាងនូវកម្រងសំណួរសម្រាប់សិក្សាពីតម្រូវការជំនាញ តាម Google Form ដើម្បីត្រៀមធ្វើផែនការបណ្តុះបណ្តាលឆ្នាំ២០២៦។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនៃវិមានព្រឹទ្ធសភា រួមមាន៖
    - បានធ្វើ Logo សមាជរដ្ឋសភា និងព្រឹទ្ធសភា ដាក់នៅសាលជំនួបភ្ញៀវអគារក្រហម។
    - បានជួសជុលដំបូលប្រេះបែក នៅសាលសិក្ខាសាលាខាងជើង។
    - បានក្រាលថ្មម៉ាបខាងមុខសាលសិក្ខាសាលាខាងជើង និងក្រោមដើមជ្រៃជាប់ចំណតរថយន្ត។
    - បានប្តូរកៅរ៉ូបាត និងកែងអូតូទ្វារ នៅនាយកដ្ឋានគ្រប់គ្រងអគារ សារពើភ័ណ្ឌ និងសំណង់ និង
    - បានសហការជាមួយអង្គភាពលូ ទឹក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ ដើម្បីបូម ស្តារប្រព័ន្ធលូ នៅក្រោយអគារជប៉ុនJ2 និងមុខអគារនាយកដ្ឋានភូមិភាគ និងសម្ភូហភាពដែនដី។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្ដាញទឹក បណ្ដាញអគ្គិសនី ត្រួតពិនិត្យជណ្ដើរយន្ត កំចាត់សត្វកណ្ដៀរ រៀបចំ និងផ្លាស់ប្ដូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៩៧គ្រឿង/លើក។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្ដាហ៍ម្ដង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែឧសភា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្ដីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា ឆ្នាំ២០២៥។

## ៤.៣-ការងារសេវាច្បាប់៖

- បានទទួលអនុក្រឹត្យ ប្រកាស សេចក្ដីសម្រេច សារាចរ និងលិខិតផ្សេងៗ ចំនួន៦ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្ដីព្រាងច្បាប់ពីទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួន១ច្បាប់ ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។
- បានធ្វើកំណត់ហេតុពិស្ដារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ និងកិច្ចប្រជុំគណៈកម្មការពិសេស ចំនួន៥លើក។
- បានប្រមូលផ្ដុំចងក្រងឯកសារ លិខិតបទដ្ឋាននានា និងបោះពុម្ពសៀវភៅ ស្ដីពី៖
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
  - ច្បាប់ស្ដីពី លក្ខន្តិកៈសមាជិកព្រឹទ្ធសភា និង
  - ច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា។
- បានផ្ដល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ និងធ្វើរបាយការណ៍ជូនគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២២២លើក។
- បានប្រគល់ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ជូនខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងបុគ្គលជាប់កាតព្វកិច្ចប្រកាស ចំនួន៦ច្បាប់ និង
- បានសម្របសម្រួលផ្ទៀងផ្ទាត់ ចុះបញ្ជី និងបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទទួលការតែងតាំងថ្មីទៅអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន៣នាក់។

## ៤.៤-ការងារស្រាវជ្រាវ៖

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន២៦ច្បាប់ រួមមាន៖
  - សេចក្តីព្រាងច្បាប់ស្តីពី ផលផល។
  - សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអភិវឌ្ឍន៍នានា ចំនួន២៤ច្បាប់ និង
  - សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។
- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធ តាមវិស័យនានា។
- បានសិក្សាស្រាវជ្រាវ រៀបចំឯកសារ និងធ្វើបទបង្ហាញជូន៖
  - សមាជិក សមាជិកាក្រុមទី៤នៃក្រុមសមាជរដ្ឋសភា និងព្រឹទ្ធសភា ចំនួន៣ប្រធានបទ រួមមានវិស័យកសិកម្ម វិស័យគាំពារសង្គម និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង
  - គណៈកម្មការទី២ព្រឹទ្ធសភាស្តីពី ការវិភាជន៍ថវិកាជាតិដល់រដ្ឋបាលឃុំ-សង្កាត់។
- បានតាមដានអំពី៖
  - ការអនុវត្តច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ និងការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និង
  - ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន៣១២ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ១៧-២២ ឆ្នាំ២០២៤)។

## ៤.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១០លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,២៤៥លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន៣២៥សកម្មភាព។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃព្រឹទ្ធសភា ចំនួន១,១៨៩ប្រធានបទ។

- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មាន ក្នុងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ជំនួបសម្ដែងការគួរសម ពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៦លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ១០លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែឧសភា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រស្ដីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន៣៤ចំណាងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១២៣គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៥៨លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន១១ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ បោះត្រាបិទប័ណ្ណខ្ទី និងសងសៀវភៅ ចំនួន២២ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៧២ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៧នាក់ (ដោយគិតត្រឹមខែឧសភា ឆ្នាំ២០២៥) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ចែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១៣ ចំនួន៨៨១ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន១២សំណុំលិខិត។

### ៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៥៤លើក។
- បានរៀបចំសារលិខិតថ្វាយព្រះពរ លិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងលិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងថ្នាក់ដឹកនាំតាមក្រសួង និងស្ថាប័ននានា ចំនួន១១លិខិត។
- បានបកប្រែឯកសារជាភាសាអង់គ្លេស រៀបចំកំណត់បង្ហាញ និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៨ច្បាប់/លើក។

- បានផលិត និងផ្សព្វផ្សាយ "ព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែឧសភា ឆ្នាំ២០២៥" ចំនួន ១ច្បាប់ និង
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៦ច្បាប់។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការជូនក្រុមគ្រួសារសមាជិកព្រឹទ្ធសភា នាយករង និងជំនួយការខុទ្ទកាល័យឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥រូប។
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌នៅខាងមុខស្ថាប័នព្រឹទ្ធសភា និងចងបដា ពាក្យស្លោក ក្នុងឱកាសនៃពិធីបុណ្យផ្សេងៗ ចំនួន៤លើក។

**៤.៧-ការងារអគ្គាធិការដ្ឋានៈ**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែឧសភា ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែឧសភា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៣៨លើក ប្រចាំសប្តាហ៍ ចំនួន ៤លើក និងប្រចាំខែឧសភា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែមិថុនា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន២៥ច្បាប់៖
    - ១- សេចក្តីព្រាងច្បាប់ស្តីពី ការទទួលខុសត្រូវលើផលិតផលមានវិការៈ និង
    - ២-សេចក្តីព្រាងច្បាប់ ចំនួន២៤ច្បាប់ ពាក់ព័ន្ធនឹងការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអភិវឌ្ឍន៍នានា។

- ត្រៀមរៀបចំកិច្ចប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើ សេចក្តីព្រាងច្បាប់ ចំនួន២៥ច្បាប់។
- ត្រៀមប្រជុំផែនការថវិការបស់ព្រឹទ្ធសភា ឆ្នាំ២០២៦ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
- ត្រៀមរៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា។

## ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការ ជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

## ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានី ភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមព្រះរាជពិធីបុណ្យ ចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន និងសិស្ស និស្សិត ដើម្បីសិក្សាឈ្វេងយល់អំពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពី កិច្ចការនយោបាយនៃសភាតំបន់អាស៊ី (APA) នៅទីក្រុង Mashhad ប្រទេសអ៊ីរ៉ង់ និង
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី ជំនាញកត់ត្រា និងជំនាញសំខាន់ៗជាច្រើនទៀត។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខ ផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញ មុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តការចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ខែឧសភា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តោតអាទិភាពលើការផ្តល់សេវាដើម្បីត្រៀមលក្ខណៈឆ្ពោះទៅរកការរៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា នាថ្ងៃទី២ ទី៣ ខែមិថុនា ឆ្នាំ២០២៥ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល ដោះស្រាយការងាររបស់ប្រទេសជាតិ។

ចំពោះវិស័យការទូតសភា សម្រេចបានលទ្ធផលយ៉ាងច្រើនសន្ធឹកសន្ធាប់ ប្រកបដោយផ្លែផ្កា តាមរយៈដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់សាធារណរដ្ឋឥណ្ឌូណេស៊ី និងសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ដែលបានលើកកម្ពស់មុខមាត់កម្ពុជាបន្ថែមទៀត នៅក្នុងតំបន់ក៏ដូចជាអន្តរជាតិ និងការផ្តល់សន្ទុះថ្មីដល់កិច្ចសហប្រតិបត្តិការទ្វេភាគី។

ស្របពេលជាមួយគ្នានេះផងដែរ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភាពមមាញឹកខ្លាំងលើការផ្តល់សេវាលើមុខងារតំណាង ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះជួបពិភាក្សាការងារ និងប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គបោះឆ្នោត បានទាន់ពេលវេលា និងទទួលបានលទ្ធផលល្អប្រសើរ។

ថ្ងៃពុធ ៦កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥
**អគ្គលេខាធិការ**

**ឡាយ សំកុល**